01178362


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire


ឯកសារលេខ៖ D236/1/1/8

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ២០)

ចំពោះមុខ: **ចៅក្រម ប្រាក់ គីមសាន** **ជាប្រធាន**
**ចៅក្រម** BEAUVALLET Olivier
**ចៅក្រម នៃយ ថុល**
**ចៅក្រម** BWANA Steven James
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥


ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 12 / 2015
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA


## សម្ងាត់

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិសុំពិចារណាឡើងវិញ និងសុំលុបចោលដីកាកោះ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍:**

ប៊ិត សៀងលីម
John R.W.D. JONES

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី:**

ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
ស៊ិន សុវ៉ន

Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
François GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE
Emmanuel JACOMY


អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

01178363



**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម (ម្ចាស់បណ្ដឹងឧទ្ធរណ៍) ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិរបស់អ្នកស្រី ស្នើសុំឱ្យពិចារណាឡើងវិញ និងលុបចោលដីកាកោះហៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤" ដែលសហមេធាវីរបស់គាត់បានដាក់នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥ ("បណ្ដឹងឧទ្ធរណ៍")[1]។

## I. **សាវតារនីតិវិធី**

1. នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតបានចុះកំណត់ហេតុនៃការខ្វែងយោបល់គ្នា ("ការខ្វែងយោបល់គ្នា")[2]។ មេធាវីការពារក្ដីលើកឡើងថា មេធាវីការពារក្ដីមិនបានដឹងពីប្រធានបទនៃការខ្វែងយោបល់គ្នានេះឡើយ[3]។ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤ ម្ចាស់បណ្ដឹងឧទ្ធរណ៍ បានដាក់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតនូវសំណើសុំបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវ ការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើម្ចាស់បណ្ដឹងឧទ្ធរណ៍ គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ[4]។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបនៅក្នុងលិខិតរួមមួយ ("សេចក្ដីបញ្ជាក់រួមគ្នា") ដោយបានលើកឡើងថា i) "ការងារផ្ទៃក្នុងនៃការិយាល័យសហចៅក្រមស៊ើបអង្កេតគឺជាការសម្ងាត់" ii) ផ្ទុយពីការស្នើឡើងរបស់លោកមេធាវី តាមវិធាន ៧២ នៃវិធានផ្ទៃក្នុង សេចក្ដីសម្រេចរបស់ចៅក្រមម្នាក់នៅក្នុងការបញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះគឺជា

---

[1] បណ្ដឹងឧទ្ធរណ៍របស់អ្នកស្រី អ៊ឹម ចែម ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើញត្តិរបស់អ្នកស្រី ស្នើសុំឱ្យពិចារណាឡើងវិញ និងលុបចោលដីកាកោះហៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ D236/1/1/2។

[2] ដីកាសម្រេចលើញត្តិរបស់ អ៊ឹម ចែម ស្នើសុំឱ្យពិចារណាឡើងវិញ និងលុបចោលដីកាកោះ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ("ដីកាសម្រេចដែលត្រូវបានជំទាស់") ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D236/1 កថាខណ្ឌ ១។ សូមមើល ដីកាកោះឱ្យ អ៊ឹម ចែមបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ A150។

[3] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១។ បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៧។

[4] សំណើសុំបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ A122។

ឆន្ទានុសិទ្ធិ ហើយរហូតដល់ពេលដែលការបញ្ជូនខាងលើនេះត្រូវបានធ្វើឡើង ខ្លឹមសារនៃសៀវភៅការខ្វែងយោបល់គ្នានៅតែជា បញ្ហាផ្ទៃក្នុង និងសម្ងាត់នៃ [ការិយាល័យសហចៅក្រមស៊ើបអង្កេត] iii) រយៈពេល ៣០ ថ្ងៃដែល មានចែងនៅក្នុងអនុវិធាន ៧២(៣) បានកន្លងផុតហើយ ដោយគ្មានការបញ្ជូនការខ្វែងយោបល់ណាមួយទៅអង្គបុរេជំនុំជម្រះនោះទេ[5]។

2. នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងដល់សហមេធាវីថា ដីកាកោះនឹងប្រគល់ជូនជនសង្ស័យដោយផ្ទាល់ក្នុងពេលសមស្របខាងមុខ លើកលែងតែសហមេធាវីបានជូនដំណឹងមកការិយាល័យសហចៅក្រមស៊ើបអង្កេតឱ្យបានត្រឹមថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៤ ថា ជនសង្ស័យបានផ្តល់សិទ្ធិឱ្យពួកគេទទួលដីកាកោះនេះជំនួសគាត់[6]។ នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤ សហមេធាវី i) បានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតថា ដីកាកោះគួរប្រគល់ជូនជនសង្ស័យដោយផ្ទាល់ ii) បានស្នើសុំឱ្យចម្លងដីកាកោះប្រគល់ជូនពួកគេឱ្យបានឆាប់តាមជាក់ស្តែង ក្រោយការប្រគល់ដីកាកោះនេះ និង iii) បានលើកឡើងថា ពួកគេចាត់ទុកដីកាកោះដែលបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ថាគ្មានសុពលភាព[7]។

3. នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៤ សហមេធាវីបានដាក់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតនូវញត្តិស្នើសុំការបញ្ជាក់បំភ្លឺទាក់ទងនឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតលើវិធាន ៧២ នៃវិធានផ្ទៃក្នុង និងការខ្វែងយោបល់គ្នាដែលសហចៅក្រមស៊ើបអង្កេតអាចមាននៅក្នុងសំណុំរឿង ០០៤ ("សំណើសុំបញ្ជាក់បំភ្លឺ")[8]។

---

[5] ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំបញ្ចូលសហចៅក្រមស៊ើបអង្កេតទាំងពីររូបនៅក្នុងទំនាក់ទំនងទាំងអស់ជាផ្លូវការទាក់ទិននឹងអ្នកស្រី អ៊ឹម ចែម និងស្នើថា ការខ្វែងយោបល់គ្នាមួយចំនួនដែលទាក់ទិននឹងការកោះហៅ និងការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម គួរត្រូវបានបញ្ជូនទៅកាន់អង្គបុរេជំនុំជម្រះ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ A122/1។

[6] លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងការរៀបចំការបង្ហាញខ្លួនលើកដំបូងរបស់ជនសង្ស័យ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ ឯកសារ A122/2។

[7] លិខិតរបស់មេធាវីការពារក្តីទាក់ទងនឹងទម្រង់បែបបទនៃការប្រគល់ដីកាកោះ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ A122/5។

[8] ញត្តិរបស់ អ៊ឹម ចែម ស្នើសុំឱ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ D204។

4. នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាកោះឱ្យបង្ហាញខ្លួនលើកដំបូងនៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ដែលត្រូវបានប្រគល់ជូនជនសង្ស័យដោយផ្ទាល់នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ ("ដីកាកោះ")[9]។ នៅក្នុងដីកាកោះនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់នូវការខ្វែងយោបល់គ្នា។ នៅថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកោះហៅសហមេធាវីឱ្យមានវត្តមាននៅពេលកូនក្តីរបស់សហមេធាវីបង្ហាញខ្លួនលើកដំបូង[10]។

5. នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីបានសរសេរលិខិតផ្ញើជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយបានលើកឡើងថា ពួកគេនឹងចាត់ទុកថា ដីកាកោះដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាងគ្មានសុពលភាពទេ រហូតដល់ពេលសហចៅក្រមស៊ើបអង្កេតធ្វើការឆ្លើយតបទៅនឹងសំណើសុំបញ្ជាក់បំភ្លឺ ហើយ "បានបដិសេធចំពោះការអញ្ជើញសហមេធាវីចូលរួមនៅក្នុងការបង្ហាញខ្លួនលើកដំបូងរបស់ពួកគេដូចបានកំណត់"[11]។

6. នៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីបានដាក់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតនូវសំណើសុំបន្ទាន់ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះទៅអង្គបុរេជំនុំជម្រះ ("សំណើសុំមោឃភាព")[12]។ សហមេធាវីបានផ្អែកលើវិធាន ៤៨ និងវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង ដើម្បីជាមូលដ្ឋានសម្រាប់សំណើសុំមោឃភាពនេះ ហើយបានស្នើសុំឱ្យផ្អាកដីកាកោះម្ចាស់បណ្តឹងឧទ្ធរណ៍ និងសហមេធាវីរបស់គាត់ រង់ចាំរហូតដល់សហចៅក្រមស៊ើបអង្កេត ក) បញ្ជូន

---

[9] ដីកាកោះឱ្យ អ៊ឹម ចែម បង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ A150។ *សូមមើលផងដែរ* កំណត់ហេតុនៃការប្រគល់ដីកាកោះ ("កំណត់ហេតុនៃការប្រគល់ដីកាកោះ") ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ ឯកសារ A150/1។

[10] ដីកាកោះមេធាវី អ៊ឹម ចែម ដើម្បីចូលរួមក្នុងពេល អ៊ឹម ចែម បង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ A151។

[11] លិខិតឆ្លើយតបទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិកោះអញ្ជើញមេធាវី ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៤ ឯកសារ A151/2។

[12] សំណើសុំបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះហៅអ្នកស្រី និងសហមេធាវីការពារក្តីគាត់ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ទៅអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៤ ឯកសារ D207។



E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

សំណើសុំមោឃភាពលើដីកាកោះទៅអង្គបុរេជំនុំជម្រះ និង ខ) បញ្ជាក់អំពីលក្ខណៈនៃការខ្វែងយោបល់គ្នានេះសិន[13]។

7. នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីការពារក្តីបានដាក់សំណើសុំបន្ទាន់មួយទៀតសុំព្យួរការអនុវត្តដីកាកោះនៅចំពោះមុខអង្គបុរេជំនុំជម្រះ បានលើកទឡ្ហីករណ៍ថា ដីកាកោះនេះពុំមានសុពលភាព ដោយហេតុថា "ការចេញដីកាកោះដោយសហចៅក្រមស៊ើប អង្កេតអន្តរជាតិតែម្នាក់ឯង ហើយក្នុងកាលៈទេសៈមួយដែលមិនទាន់មានការបញ្ជាក់អំពីលក្ខណៈនៃការខ្វែងយោបល់គ្នារវាងរូបគាត់ និងសហចៅក្រមស៊ើបអង្កេតជាតិ ទៅតាមសំណើសុំរបស់ មេធាវីការពារក្តីនោះអាចត្រូវបានចាត់ទុកថាជាការមិនគោរពវិធានបញ្ញត្តិ ដែលពិតជាប៉ះពាល់ដល់យុត្តិធម៌នៃដំណើរការនីតិវិធីទាំងមូលនៅក្នុងសំណុំរឿងទាក់ទិននឹងម្ចាស់បណ្តឹងឧទ្ធរណ៍ ព្រមទាំងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់អ្នកស្រី អ៊ឹម ចែម ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី" ("សំណើសុំព្យួរ")[14]។ នៅថ្ងៃដដែលនោះ អង្គបុរេជំនុំជម្រះបានច្រានចោលសំណើសុំព្យួរនេះ[15] ហើយបានចេញសំអាងហេតុចំពោះការច្រានចោលនេះនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ដោយបានសម្រេចថា សំណើសុំនេះពុំស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួននោះឡើយ[16]។ ដោយពិចារណាលើការប៉ះពាល់ដល់ផលប្រយោជន៍ អង្គបុរេជំនុំជម្រះបានសម្រេចថា បើទោះជាបញ្ហានេះស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួនក៏ដោយ i) ចំណុចទីមួយ សហមេធាវីការពារក្តីពុំបានបង្ហាញថា ម្ចាស់បណ្តឹងឧទ្ធរណ៍នឹងទទួលរងព្យសនកម្ម "ពុំអាចជួសជុលបាន" និង ii) ចំណុចទីពីរ មូលដ្ឋានលើកឡើងដោយសហមេធាវីការពារក្តី ក្នុងការតវ៉ាលើសុពលភាពនៃដីកាកោះ ពុំមានមូលដ្ឋាន *យោងតាមភ័ស្តុតាងបឋម* ទេ[17]។

---

[13] *ដូចខាងលើ*។

[14] សំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ ឯកសារ A122/6.1/1។

[15] សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ឯកសារ A122/6.1/2។

[16] សេចក្តីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឱ្យមកបង្ហាញខ្លួនជាលើកដំបូង ("សេចក្តីសម្រេចលើសំណើសុំព្យួរ") ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ A122/6.1/3។

[17] សេចក្តីសម្រេចលើសំណើសុំព្យួរ កថាខណ្ឌទី ១៣-១៤។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

8. ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតបានច្រានចោលសំណើសុំការបញ្ជាក់បំភ្លឺ ("ការបញ្ជាក់បំភ្លឺ")[18]។

9. ប្រហែលជាមួយម៉ោងនៅមុនពេលសវនាការបង្ហាញខ្លួនលើកដំបូងនាថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៤ ដែលបានគ្រោងទុក សហមេធាវីអន្តរជាតិរបស់ជនសង្ស័យបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិតាមរយៈអ៊ីមែលថា ក្រោយពីការច្រានចោលដោយអង្គបុរេជំនុំជម្រះលើសំណើសុំព្យួរដីកាកោះរួចមក ជនសង្ស័យនឹងស្ម័គ្រចិត្តមក អ.វ.ត.ក ដើម្បីបង្ហាញខ្លួនជាលើកដំបូងទៅតាមកាលវិភាគថ្មី។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ព្រមតាមការរៀបចំនេះ។ ក៏ប៉ុន្តែ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៤ សហមេធាវីបានជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិថា ជនសង្ស័យលែងមានឆន្ទៈចូលបង្ហាញខ្លួនដោយស្ម័គ្រចិត្តនៅ អ.វ.ត.ក ទៅតាមដីកាកោះដែលបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិតែម្ដងទៀតហើយ[19]។ នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាបង្គាប់ឱ្យនាំខ្លួន ដើម្បីធានាវត្តមានរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍នៅក្នុងពេលបង្ហាញខ្លួនលើកដំបូងនៅតុលាការនេះ[20]។

10. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចច្រានចោលសំណើសុំមោឃភាពដីកាកោះដោយចាត់ទុកថាមិនអាចទទួលយកសំណើនេះបានឡើយ ហើយបានសម្រេចថា ជនសង្ស័យពុំមានសិទ្ធិដាក់សំណើសុំមោឃភាពបែបនេះឡើយ ("ដីកាសម្រេចលើសំណើសុំមោឃភាព")[21]។ បើទោះជាសម្រេចថា សំណើសុំមោឃភាពមិនអាចទទួលយកបានក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ថា "ដោយគិតដល់ភាពច្បាស់លាស់នៃច្បាប់ និងយុត្តិសាស្ត្រស្ដីពីសុពលភាពនៃដីកាកោះដែលចេញដោយ ស.ច.ស តែម្នាក់

---

18 ដីកាសម្រេចលើញត្តិរបស់ជនសង្ស័យស្នើសុំឱ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៤ ឯកសារ D204/2។

19 កំណត់ត្រារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងការបង្ហាញខ្លួនលើកដំបូងរបស់លោកស្រី អ៊ឹម ចែម ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ឯកសារ A150/2។

20 ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ដែលបានដាក់នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ C1។

21 ដីកាសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យបញ្ជូនសំណើសុំមោឃភាពដីកាកោះអ្នកស្រី និងសហមេធាវីការពារក្ដីគាត់ទៅអង្គបុរេជំនុំជម្រះ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ D207/1 កថាខណ្ឌ ៣២, [illegible]



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C • C.E.T.C

01178368



ហើយកាន់តែច្បាស់ទៀត តាមរយៈ[សេចក្ដីសម្រេចលើការព្យួរដីកាកោះ]នោះ ទើប ស.ច.ស អន្តរជាតិមិន "ជឿជាក់ថា សំណើបានបំពេញតាមលក្ខខណ្ឌដែលត្រូវបញ្ជូនបន្ត [ទៅ អ.ប.ជ] អនុលោមតាមវិធានផ្ទៃក្នុង ៧៦ ឡើយ"[22]។ គ្មានបណ្ដឹងឧទ្ធរណ៍ណាមួយត្រូវបានធ្វើឡើងប្រឆាំងនឹងដីកាសម្រេចលើសំណើសុំមោឃភាពនេះឡើយ។

11. នៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៥ សហមេធាវីការពារក្ដីបានដាក់នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេតនូវញត្តិស្នើសុំឱ្យពិចារណាឡើងវិញ និងលុបចោលដីកាកោះ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ ("ញត្តិស្នើសុំឱ្យពិចារណាឡើងវិញ")[23] ដោយបានតវ៉ាលើភាពអាចទទួលយកបាននៃញត្តិនេះផ្អែកលើមូលដ្ឋានចំនួនពីរ i) "តាមអំណាចឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការពិចារណាឡើងវិញលើសេចក្ដីសម្រេចពីមុនរបស់ខ្លួន"[24] ក្នុងករណីសេចក្ដីសម្រេចដែលបានធ្វើឡើងពីមុនៗមានវិការៈ ឬ បណ្ដាលឱ្យមានភាពអយុត្តិធម៌[25] ii) និងវិធាន ២១ នៃវិធានផ្ទៃក្នុងដែលធានានូវសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានសាលាក្ដីដែលមានសមត្ថកិច្ច[26]។

12. នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចដែលត្រូវបានជំទាស់ ច្រានចោលញត្តិស្នើសុំឱ្យពិចារណាឡើវិញនេះ ហើយបានសន្និដ្ឋានថា "ដីកាកោះមិនមានការភាន់ច្រឡំ មិនប៉ះពាល់ដល់ជនសង្ស័យ ហើយក៏មិនប៉ះពាល់ដល់ការប្រើប្រាស់សិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែរ"[27]។ នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ

---

[22] *ដូចខាងលើ* កថាខណ្ឌ ៣៤។

[23] ញត្តិរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យពិចារណាឡើងវិញ និងលុបចោលដីកាកោះហៅអ្នកស្រីចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៥ ឯកសារ D236 កថាខណ្ឌចុងក្រោយ។

[24] ញត្តិស្នើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ១៣ *យោងលើ* យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ។

[25] ញត្តិស្នើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ១៤-១៥។

[26] ញត្តិស្នើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ១៣, ១៦។

[27] ដីកាសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ២៤។

២០១៥ សហមេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ប្តឹងប្រឆាំងនឹងដីកា សម្រេចដែលត្រូវបានជំទាស់នេះ[28]។

13. នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ដោយចោទប្រកាន់គាត់ដូចបានបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងស្តីពីបទចោទ និងបានអនុញ្ញាតឱ្យសហមេធាវីការពារក្តីរបស់គាត់មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ("ដីកាសម្រេចដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ")[29]។

14. នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៥ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេសតែប៉ុណ្ណោះ ដោយបានដាក់សំណើបឋមសុំការអនុញ្ញាតដាក់សំណៅភាសាអង់គ្លេសជាមុនសិន ហើយសំណៅបកប្រែជាភាសាខ្មែរនឹងត្រូវដាក់ជូនតាមក្រោយ។ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ អង្គបុរេជំនុំជម្រះបានយល់ព្រមតាមសំណើសុំបឋមរបស់សហមេធាវីការពារក្តី ហើយបណ្តឹងឧទ្ធរណ៍ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងភាសាខ្មែរនៅថ្ងៃតែមួយ។ នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ ឆ្លើយតបទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះ[30] សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបរបស់ពួកគេតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះ ("ចម្លើយតប ក.ស.ព") [31]។ សហមេធាវីការពារក្តីបានដាក់ការឆ្លើយតបរបស់ពួកគេនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥

---

[28] សៀវភៅចុះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon លើញត្តិរបស់អ្នកស្រី អ៊ឹម ចែម ស្នើសុំឱ្យពិចារណាឡើងវិញ និងលុបចោលដីកាកោះហៅអ្នកស្រី ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤, ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០១៥ ឯកសារ D236/1/1 ។

[29] ដីកាសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D239 ។

[30] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលកំណត់ក្នុងការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម និងសំណើរបស់មេធាវី ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D236/1/1/5។

[31] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍ អ៊ឹម ចែម ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធញត្តិរបស់គាត់សុំឱ្យពិចារណាឡើងវិញ និងលុបចោលដីកាកោះ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D236/1/1/6។



PRE-TRIAL CHAMBER • CHAMBRE PRÉLIMINAIRE • E.C.C.C • C.E.T.C

ជាភាសាអង់គ្លេសតែប៉ុណ្ណោះ និងជាភាសាខ្មែរនៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១៥ (“ការឆ្លើយតប”)[32]។

## II. សារណា

15. សហមេធាវីការពារក្ដីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (ក) ទទួលយកសារណារបស់មេធាវីការពារក្ដីជាបណ្ដឹងឧទ្ធរណ៍អនុលោមតាមវិធាន ២១ និងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង (ខ) ច្រានចោលដីកាសម្រេចដែលត្រូវបានជំទាស់ ដែលមានកំហុសអង្គច្បាប់ និង (គ) លុបចោលដីកាកោះម្ចាស់បណ្ដឹងឧទ្ធរណ៍ ដែលចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។ សហមេធាវីការពារក្ដីតវ៉ាលើភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍នេះ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[33] ដើម្បីធានាសិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្នុងការទទួលបានសាលាក្ដីមានសមត្ថកិច្ច និងអនុលោមតាមវិធាន ៧៤ (៣)(ក) នៃវិធានផ្ទៃក្នុង[34] ដោយហេតុថា សិទ្ធិទទួលបានសាលាក្ដីមានសមត្ថកិច្ចមានន័យថាសាលាក្ដីត្រូវមានយុត្តាធិការលើបញ្ហាជាក់លាក់។

16. សហមេធាវីការពារក្ដីតវ៉ាថា “ព្យសនកម្មដែលមិនអាចជួសជុលបាន[បានបង្កនូវផលប៉ះពាល់]លើសិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍” ដោយសារតែកំហុសអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការមិនបានទទួលស្គាល់ថា ការខ្វះនូវព័ត៌មានអំពីការខ្វែងយោបល់គ្នាបានប៉ះពាល់លើសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយសាលាក្ដីមានសមត្ថកិច្ច ដោយមិនឱ្យគាត់មានលទ្ធភាពតវ៉ាអំពីសមត្ថកិច្ចរបស់ចៅក្រមក្នុងការបំពេញកិច្ចតែម្នាក់ឯង[35]។ តុលាការមានកាតព្វកិច្ចផ្ដល់ព័ត៌មានបែបនេះ ដោយសារមានភស្តុតាងបង្ហាញថា បញ្ហាកើតមានចំពោះជនត្រូវចោទស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការ[36] ហើយតុលាការត្រូវមានកាតព្វកិច្ចបង្ហាញថាតុលាការបានអនុវត្តតាមវិធាន ៧២(៣) នៃវិធានផ្ទៃក្នុង ដែលបានកម្រិតសមត្ថកិច្ចរបស់សហ

---

[32] ការឆ្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះបណ្ដឹងឧទ្ធរណ៍របស់អ្នកស្រីប្រឆាំងនឹងដីកាកោះ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D236/1/1/7។

[33] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៦-១៩។

[34] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២០-២១។

[35] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៧, ១៨។ *សូមមើលផងដែរ* កថាខណ្ឌ ២៦, ៣១។

[36] *ដូចខាងលើ*។

ចៅក្រមស៊ើបអង្កេតក្នុងការ "បំពេញកិច្ចដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នា"[37]។ យោងតាមសហមេធាវីការពារក្តី បទប្បញ្ញត្តិស្តីពីការខ្វែងយោបល់គ្នាដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Harmon បំពេញកិច្ចតែម្នាក់ឯងបាន ក៏ត្រូវផ្តល់សិទ្ធិដោយប្រយោលឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍បានដឹងអំពីលក្ខណៈពិតប្រាកដនៃការខ្វែងយោបល់គ្នា ដើម្បីអនុវត្តសិទ្ធិរបស់គាត់ក្នុងការទទួលបានសាលាក្តីដោយមានសមត្ថកិច្ច។ សិទ្ធិនេះគឺជាសិទ្ធិដាច់ខាត និង "ពុំមែនជាកម្មវត្ថុនៃករណីលើកលែងណាមួយនោះឡើយ"[38]។ សហមេធាវីការពារក្តីបានបញ្ជាក់ថា ពួកគេគ្មានការសង្ស័យអំពី ឬបានព្យាយាមជំទាស់ឯករាជ្យភាព ឬអព្យាក្រឹត្យភាពរបស់ចៅក្រម[39]ទេ ហើយបានអះអាងថា ការខូចខាតដែលបានបង្កឡើងលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដោយសារតែកំហុសដូចបានចោទប្រកាន់ ពុំអាចជួសជុលបានទេ ដោយសារតែការពុំចូលបង្ហាញខ្លួនរបស់គាត់[40] ត្រូវបានយកមកប្រើប្រាស់ដើម្បីផ្តល់យុត្តិកម្មដល់ការចេញដីកាបង្គាប់ឱ្យនាំខ្លួនរួចហើយ[41]។

17. នៅក្នុងចម្លើយតប សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលបណ្តឹងឧទ្ធរណ៍នេះ[42] ហើយលើកទឡ្ហីករណ៍ថា ទោះបីជាពុំមានសិទ្ធិចូលពិនិត្យមើលការខ្វែងយោបល់គ្នាក៏ដោយ ក៏ម្ចាស់បណ្តឹងឧទ្ធរណ៍នៅតែមានលទ្ធភាពវាយតម្លៃយ៉ាងប្រាកដអំពីសមត្ថកិច្ចរបស់ចៅក្រម Harmon ដោយសារថាវាបង្ហាញច្បាស់ថា តាមរយៈការចេញដីកាកោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំពេញកិច្ចអនុលោមតាមលក្ខខណ្ឌតម្រូវនៃក្របខណ្ឌគតិយុត្តិស្តីពីការខ្វែងយោបល់គ្នា[43]។

18. ជាការឆ្លើយតប សហមេធាវីការពារក្តីលើកឡើងសំណើសុំរបស់ពួកគេឡើងវិញឱ្យអង្គបុរេជំនុំជម្រះយល់ព្រមតាមបណ្តឹងឧទ្ធរណ៍ និងលុបចោលដីកាកោះ[44]។ សហមេធាវីការពារក្តីសន្និដ្ឋានថា

---

[37] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៦ *យោង*ញត្តិស្នើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ២៣-២៤។

[38] ញត្តិស្នើសុំឱ្យពិចារណាឡើងវិញ កថាខណ្ឌ ២៩-៣០។

[39] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៣។

[40] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១០។

[41] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩។

[42] ចម្លើយតប កថាខណ្ឌ ១៥។

[43] ចម្លើយតប កថាខណ្ឌ ៨-៩, ១៣។

[44] ការឆ្លើយតប ទំព័រ ៥ កថាខណ្ឌចុងក្រោយ។

i) ចៅក្រមមានភារកិច្ចយល់ព្រមឱ្យចូលពិនិត្យមើលការខ្វែងយោបល់គ្នា ដើម្បីអាចឱ្យវាយតម្លៃលើសមត្ថកិច្ចរបស់ចៅក្រម[45] ii) ការខកខានមិនគោរពតាមភារកិច្ចបែបនេះ ចៅក្រមមានកំហុសអង្គច្បាប់ និងបានរំលោភលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការតវ៉ាលើសមត្ថកិច្ចរបស់ចៅក្រម[46] និង iii) ការរំលោភបែបនេះនឹងមោឃភាពដីកាកោះ ហេតុដូច្នេះ ដីកាកោះនេះត្រូវតែត្រូវលុបចោល[47]។

## III. ភាពទទួលយកបាន

19. មេធាវីការពារក្តីស្នើសុំឱ្យអង្គបុរេជំនុំជម្រះមេត្តាទទួលយកបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ និង ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[48]។ អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលថាតើ បណ្តឹងឧទ្ធរណ៍ស្ថិតក្នុងយុត្តាធិការរបស់ខ្លួន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ឬយ៉ាងណា មុននឹងពិនិត្យមើលថាតើ កាលៈទេសៈនៃរឿងក្តីនេះតម្រូវឱ្យអង្គជំនុំជម្រះធ្វើអន្តរាគមន៍អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីការពារសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ឬយ៉ាងណា។

### ក) ភាពអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង

20. អនុលោមតាមវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង "ជនត្រូវចោទ ឬជនជាប់ចោទ អាចធ្វើបណ្តឹងឧទ្ធរណ៍ [...] ប្រឆាំងនឹងដីកា ឬ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត [...] ដោយបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក"[49]។ ក្នុងការបកស្រាយវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា មានតែការជំទាស់ទៅលើបញ្ហាយុត្តាធិការទេដែលអាចត្រូវ

---

[45] ការឆ្លើយតប កថាខណ្ឌ ១០, ១៣។

[46] ការឆ្លើយតប កថាខណ្ឌ ១៣។

[47] *ដូចខាងលើ*។

[48] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥។

[49] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី") ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៤។

01178373



បានលើកឡើងអនុលោមតាមវិធាននេះ[50]។ បញ្ហាទីមួយដែលត្រូវដោះស្រាយគឺថាតើ ដីកាសម្រេចដែលរងការជំទាស់ គឺជាការសម្រេចដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក ឬយ៉ាងណា។

21. សហមេធាវីការពារក្ដីលើកទឡ្ហីករណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះថា សិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ក្នុងការទទួលបានសាលាក្ដីមានសមត្ថកិច្ចក៏មានន័យផងដែរថា "តុលាការដែលជំនុំជម្រះលើរឿងក្ដីរបស់គាត់ ចាំបាច់ត្រូវមានយុត្តាធិការទៅលើបញ្ហាដាក់លាក់ចោទជាបញ្ហា ហើយយុត្តាធិការជាឯកតោភាគីរបស់សហចៅក្រមស៊ើបអង្កេត Harmon ក្នុងការចេញដីកាកោះ ត្រូវបានកម្រិតនៅក្នុងលក្ខខណ្ឌនៃការខ្វែងយោបល់គ្នា"[51]។ សហមេធាវីលើកជាទឡ្ហីករណ៍ថា បណ្ដឹងឧទ្ធរណ៍ស្ថិតនៅក្រោមបទប្បញ្ញត្តិនៃវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ដោយផ្អែកលើមូលដ្ឋានថា "ចៅក្រម Harmon បានអះអាងដោយមិនច្បាស់លាស់ថា គាត់មានយុត្តាធិការក្នុងការកោះហៅ [ម្ចាស់បណ្ដឹងឧទ្ធរណ៍] ដោយមិនបានបង្ហាញភស្តុតាងឡើយពីការមានយុត្តាធិការរបស់គាត់ តាមរយៈការមិនបង្ហាញនូវព័ត៌មានអំពីការខ្វែងយោបល់គ្នាចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤"[52]។

22. តាំងពីដំបូងមក គួររម្លឹកថា កិច្ចដំណើរការនីតិវិធីទាំងនេះមានប្រភពមកពីសំណើមួយរបស់សហមេធាវីស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញទៅលើដីកាកោះ ដោយផ្អែកលើមូលដ្ឋានថា ការដែលមេធាវីការពារក្ដីមិនអាចចូលពិនិត្យមើលការខ្វែងយោបល់គ្នា ប៉ះពាល់ដល់លទ្ធភាពរបស់ខ្លួនក្នុងការវាយតម្លៃលើសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការចេញដីកាកោះ[53]។ ការអនុវត្តសេចក្ដីសម្រេចមុនៗរបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងលទ្ធភាពរបស់ភាគីក្នុងការចូលពិនិត្យមើលការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិនិត្យមើលថាតើ ការមិនមានលទ្ធភាពចូលពិនិត្យមើលការខ្វែងយោបល់គ្នាបណ្ដាលឲ្យប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ ក្នុងការទទួលបានការជំនុំ

---

[50] សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ២១។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ៤៥, ៤៧។ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៦០។

[51] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២០។

[52] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២១។

[53] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១២។

ជម្រះដោយយុត្តិធម៌ ដែលត្រូវបានធានាដោយវិធាន ២១ នៃវិធានផ្ទៃក្នុង ឬយ៉ាងណា។ គាត់បានសន្និដ្ឋានថា ករណីនេះមិនបានកើតឡើងទេ ដោយសារតែនីតិវិធីនៃការខ្វែងយោបល់គ្នាត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ហើយក្របខណ្ឌច្បាប់មានការធានាពេញលេញ ដើម្បីធានាឲ្យមានការគោរពតាមលក្ខខណ្ឌតម្រូវចំពោះកិច្ចជាឯកតោភាគី[54]។

23. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ខ្លឹមសារនៃបញ្ហានៅក្នុងករណីនេះមិនមែនជាសមត្ថកិច្ចរបស់ អ.វ.ត.ក ក្នុងការចេញដីកាកោះ ឬសូម្បីតែសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះទេ ប៉ុន្តែជាសិទ្ធិចូលពិនិត្យមើលការខ្វែងយោបល់គ្នា។ តាមពិតទៅ សហមេធាវីទទួលស្គាល់ថា សហចៅក្រមស៊ើបសួរម្នាក់អាចបំពេញកិច្ចតែម្នាក់ឯង នៅពេលដែលនីតិវិធីនៃការខ្វែងយោបល់គ្នាត្រូវបានអនុវត្ត តែអះអាងថា ការមិនអាចចូលពិនិត្យមើលការខ្វែងយោបល់គ្នា រារាំងសហមេធាវីមិនឲ្យពិនិត្យបានថាតើសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំពេញកិច្ចនៅក្នុងវិសាលភាពនៃការខ្វែងយោបល់គ្នា នៅក្នុងករណីនេះ ឬយ៉ាងណា[55]។ នៅក្នុងដីកាសម្រេចដែលរងការជំទាស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិគ្រាន់តែច្រានចោលទឡ្ហីករណ៍របស់មេធាវីការពារក្តី[56] គាត់មិនបានបញ្ជាក់ពីសមត្ថកិច្ចរបស់គាត់ក្នុងការចេញដីកាកោះ ដូចបានអះអាងដោយមេធាវីការពារក្តី ហើយគាត់ក៏មិនចាំបាច់ត្រូវធ្វើដូច្នេះដែរ។

24. ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរម្លឹករួចមកហើយ និងត្រូវបានពិភាក្សាយ៉ាងពេញលេញខាងក្រោមនេះ វិធានជាធរមានមិនអនុញ្ញាតឲ្យភាគីចូលពិនិត្យមើលការខ្វែងយោបល់គ្នាទេ ហេតុនេះ ក៏មិនអនុញ្ញាតឲ្យភាគីជំទាស់ទៅនឹងសិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបំពេញកិច្ចតែម្នាក់ឯងដែរ។ ផ្ទុយទៅវិញ វិធាន ៧២ នៃវិធានផ្ទៃក្នុងផ្តល់សិទ្ធិអំណាចយ៉ាងច្បាស់ដល់សហចៅក្រមស៊ើបអង្កេតម្នាក់ក្នុងការបំពេញកិច្ចតែម្នាក់ឯង នៅពេលដែលថិរវេលាសម្រាប់ដាក់ការខ្វែងយោបល់គ្នាសម្រាប់ដោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុតហើយ

---

[54] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០ ដល់ ២២។

[55] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៦។

[56] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៧ ដល់ ២៤។

01178375



នោះ[57]។ ក្នុងករណីនេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ការខ្វែងយោបល់គ្នាណាក៏ដោយមិនអាចដករឿងក្តីចេញពីសហចៅក្រមស៊ើបអង្កេតដែលខ្វែងយោបល់គ្នា ដែលអាចលើកការជំទាស់បានក្នុងករណីចាំបាច់[58]។ តាមពិត នៅក្នុងរឿងក្តីនេះ អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចពីមុនថា ដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតម្នាក់ ក្នុងគោលបំណងចោទប្រកាន់ មានសុពលភាព ប្រសិនបើនីតិវិធីនៃការខ្វែងយោបល់គ្នាដែលមានចែងក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុងត្រូវបានអនុវត្តរួច ហើយរយៈពេល ៣០ ថ្ងៃសម្រាប់ការដាក់សំណើនៅចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុតហើយ[59]។ ហេតុនេះ ដរាបណាការខ្វែងយោបល់គ្នាមិនត្រូវបានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ ការដែលថា ដីកា ឬសេចក្តីសម្រេចខ្លះត្រូវបានប្រតិបត្តិទៅតាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេតម្នាក់នោះ មិនមែនជាបញ្ហានៃការជំទាស់ទៅលើបញ្ហាយុត្តាធិការទេ។

25. ដោយផ្អែកលើសំអាងហេតុនានាដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាសម្រេចដែលរងការជំទាស់ ដែលបានបដិសេធសំណើរបស់មេធាវីការពារសុំឲ្យពិចារណាឡើងវិញ

---

[57] មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង។ មាត្រា ២៣ថ្មី(២) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ វិធាន ៧២(២) និង (៣) នៃវិធានផ្ទៃក្នុង។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងដីកាសម្រេចបដិសេធរបស់គាត់ស្នើសុំព័ត៌មានទាក់ទងនឹងករណីខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន") ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D208/1/1/2 កថាខណ្ឌ ១១។ សេចក្តីសម្រេចលើសំណើសុំការព្យួរដីកាកោះ កថាខណ្ឌ ១៤។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៧៤ ដល់ ២៧៦។ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ កថាខណ្ឌ ១៦, ២៧។

[58] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន កថាខណ្ឌ ១១។

[59] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត") ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D117/1/1/2 កថាខណ្ឌ ១៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ជំទាស់ទៅនឹងការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] អំពីសុពលភាពនៃដីកាកោះ") ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារ D212/1/2/2 កថាខណ្ឌ ៧។ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៧៦។

*សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្តីពីសំណើសុំឲ្យពិចារណាឡើងវិញ និងសុំលុបចោលដីកាកោះ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤*

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ទៅលើដីកា និងសុំឲ្យលុបចោលដីកាកោះ ពុំមែនជាសេចក្តីសម្រេចដែលបញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក ទេ។

26. ហេតុនេះទាក់ទិននឹងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន។

**ខ) ភាពអាចទទួលយកបានអនុលោមតាមវិធាន ២១(១) នៃវិធានផ្ទៃក្នុង**

27. សហមេធាវីបានលើកឡើងថា អង្គបុរេជំនុំជម្រះមានយុត្តាធិការស្តាប់សក្ខីកម្មលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកលើវិធាន ២១ នៃវិធានផ្ទៃក្នុង នៅពេលដែល "អន្តរាគមន៍របស់អង្គជំនុំជម្រះជាការចាំបាច់ ដើម្បីរារាំងមិនឲ្យមានព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌"[60]។ សហមេធាវីលើកឡើងបន្ថែមទៀតថា សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានសាលាក្តីមានសមត្ថកិច្ចត្រូវបានរំលោភបំពាន ដោយការខកខានមិនបានផ្តល់ព័ត៌មានស្តីពីការខ្វែងយោបល់គ្នា "ដែលជាមូលដ្ឋានរបស់ [សហចៅក្រមស៊ើបអង្កេតអន្តរជាតិ] ក្នុងការអះអាងលើសិទ្ធិអំណាចជាឯកតោភាគីរបស់គាត់ក្នុងការចេញដីកាកោះ"[61]។ សហមេធាវីលើកជាទឡ្ហីករណ៍ថា ហេតុនេះបណ្តឹងឧទ្ធរណ៍គួរត្រូវបានទទួលយក ដើម្បីការពារសិទ្ធិរបស់គាត់ក្នុងការទទួលបានសាលាក្តីមានសមត្ថកិច្ច និងដើម្បីបង្ហាញថា ដីកាកោះពុំមានសុពលភាពទេ[62]។

28. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានផ្តល់ការអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍ដោយស្វ័យប្រវត្តិ ផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះទេ[63]។ ដើម្បីឲ្យអង្គបុរេជំនុំជម្រះអាចអនុវត្តយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា ក្នុងកាលៈទេសៈពិសេសនៃរឿងក្តីនេះ ការធ្វើអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះជាការចាំបាច់ ដើម្បីការពារមិនឲ្យមានការខូចខាតដែលមិនអាចជួសជុលបានដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំ

---

[60] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។ *សូមមើល ផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន កថាខណ្ឌ ១០។

[61] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៨។ *សូមមើល ផងដែរ* ដីកាកោះ ទំព័រ ២។

[62] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៩។

[63] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន កថាខណ្ឌ ៨។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ... កថាខណ្ឌ ១៥។



PRE-TRIAL CHAMBER • E.C.C.C • C.E.T.C

ជម្រះដោយយុត្តិធម៌[64]។ ស្រដៀងគ្នាដែរ វិធាន ២១ នៃវិធានផ្ទៃក្នុងមិនអាចត្រូវបានយកទៅប្រើ ដើម្បីទទួលយកពាក្យសុំមួយដែលមានក្របខណ្ឌដែលត្រូវបានកំណត់ច្បាស់ តែពាក្យសុំនោះមិនបានបំពេញលក្ខខណ្ឌតម្រូវនៃភាពអាចទទួលយកបាននោះទេ[65]។

29. ក្នុងកាលៈទេសៈណាក៏ដោយ អង្គបុរេជំនុំជម្រះយល់ឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញនៅក្នុងរឿងក្តីនេះថា ដីកាសម្រេចដែលរងការជំទាស់ដែលបដិសេធមិនពិចារណាឡើងវិញ និងមិនលុបចោលដីកាកោះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទេ។ ការផ្តល់ព័ត៌មានទាក់ទិននឹងការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេតត្រូវស្ថិតក្នុងរង្វង់ឆន្ទានុសិទ្ធិរបស់ពួកគេ[66]។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះ "មិនត្រូវជ្រៀតជ្រែកចូលក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិនេះទេ លុះត្រាតែមានការចង្អុលបង្ហាញថា ក្នុងកាលៈទេសៈពិសេសនៃរឿងក្តី កង្វះព័ត៌មានអំពីការខ្វែងយោបល់គ្នាប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌"[67]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា លក្ខខណ្ឌតម្រូវតាម

---

[64] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] លើសំណើរបស់គាត់សុំការបំភ្លឺ") ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D205/1/1/2 កថាខណ្ឌ ៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ១៥។

[65] សូមមើល សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ តា អាន ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើរបស់គាត់ទាក់ទិននឹងពត៌មានអំពីការខ្វែងយោបល់គ្នារបស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣, ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ D208/1/1/2 កថាខណ្ឌទី ៨។ សូមមើល សំណុំរឿង ០០២ (PTC16) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំដាក់បញ្ចូលឯកសារទាំងឡាយពាក់ព័ន្ធនឹងសកម្មភាពជាក់ស្តែងរបស់លោក ខៀវ សំផន" ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ D370/2/11 កថាខណ្ឌទី ១២។

[66] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន កថាខណ្ឌ ១០ *យោងដល់ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Šešelj* សំណុំរឿងលេខ IT-03-67-T សេចក្តីសម្រេចបើករបាយការណ៍របស់ចៅក្រមជំនុំជម្រះធ្វើជូនប្រធានតុលាការ ឬជាជម្រើសម្យ៉ាងទៀត របស់ចៅក្រមដែលគាត់បានចាត់តាំង ពាក់ព័ន្ធនឹងញត្តិសុំប្តឹងដិតចិត្តចៅក្រម Harhoff ជាចៅក្រមជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូង III ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៣ ទំព័រ ៣។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić,* សំណុំរឿងលេខ IT-04-74-T ដីកាសម្រេចដោយអង្គជំនុំជម្រះរបស់ចៅក្រមជំនុំជម្រះ ទាក់ទិននឹងសំណុំរបស់មេធាវីការពារក្តី Prlić ដែលស្នើសុំដាក់បង្ហាញលិខិតប្រាស្រ័យទាក់ទងការងារ អង្គជំនុំជម្រះសាលាដំបូង III ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១០ ទំព័រ ២។

[67] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន កថាខណ្ឌ ១០។ *សូមមើល ផងដែរ* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត កថាខណ្ឌ ១៥។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] អំពីសុពលភាពនៃដីកាកោះ កថាខណ្ឌ ៦។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] លើសំណើរបស់គាត់សុំការបំភ្លឺ កថាខណ្ឌ ៧។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ផ្លូវច្បាប់សម្រាប់សកម្មភាពជាឯកតោភាគីដោយសហចៅក្រមស៊ើបអង្កេតម្នាក់ ត្រូវបានអនុវត្តតាម ហើយការខ្វែងយោបល់គ្នាមិនត្រូវបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ[68]។ លើសពីនេះទៀត ដោយពុំមានការបង្ហាញខុសពីនេះ មានការសន្មតថា ពាក់ព័ន្ធនឹងករណីកិច្ចផ្នែកតុលាការ និងក្រមសីលធម៌របស់ខ្លួន សហចៅក្រមស៊ើបអង្កេតធានាថា ពួកគេបំពេញកិច្ចអនុលោមតាមលក្ខខណ្ឌ តម្រូវនៅក្នុងមាត្រា ៥(៤) នៃកិច្ចព្រមព្រៀង មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧២ នៃវិធានផ្ទៃក្នុង[69]។

30. ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរម្លឹករួចមកហើយ វិធានជាធរមានចែងច្បាស់ថា សហចៅក្រមស៊ើបអង្កេតម្នាក់អាចបំពេញកិច្ចតែម្នាក់ឯងបាន ប្រសិនបើនីតិវិធីនៃការខ្វែងយោបល់គ្នាត្រូវបានអនុវត្តតាម[70]។ សហចៅក្រមស៊ើបអង្កេតក៏លើកឡើងច្បាស់ថា ការខ្វែងយោបល់គ្នាជាបញ្ហាផ្ទៃក្នុង ក.ស.ច.ស ហើយភាគីមិនអាចចូលពិនិត្យមើលបានទេ លុះត្រាតែការខ្វែងយោបល់គ្នាត្រូវបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ[71]។ ហេតុនេះ វិធានជាធរមានមិនបានប្រមើលមើលថា សិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេតម្នាក់ក្នុងការបំពេញកិច្ចតែម្នាក់ឯង នឹងត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ភាគីទេ លើកលែងតែមានភ័ស្តុតាងថា លក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់សម្រាប់សកម្មភាពជាឯកតោភាគីមិនត្រូវបានអនុវត្តតាម។ ផ្ទុយទៅវិញ វិធានចែងថា សហចៅក្រមស៊ើបអង្កេតទាំងពីរនាក់មានសិទ្ធិអំណាច និងករណីកិច្ចក្នុងការធានាថា សកម្មភាពដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតម្នាក់ ស្ថិតក្នុងវិសាលភាពនៃការខ្វែងយោបល់គ្នា ឬត្រូវមានការផ្ទេរសិទ្ធិអំណាច។ សហចៅក្រមស៊ើបអង្កេតត្រូវបំពេញកាតព្វកិច្ចទាំងនេះ និងបំពេញកិច្ច ដោយអនុលោមតាមករណីកិច្ចនៃក្រមសីលធម៌របស់ខ្លួន[72]។

---

[68] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៩។ សេចក្តីសម្រេចលើសំណើសុំការព្យួរដីកាកោះ កថាខណ្ឌ ១៤។ *សូមមើលផងដែរ* បណ្តឹងឧទ្ធរណ៍របស់ អៀង សារី កថាខណ្ឌ ២៧៤ ដល់ ២៧៦។ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង កថាខណ្ឌ ១៦, ២៧។

[69] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន កថាខណ្ឌ ១១។

[70] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៧ *យោងដល់* សេចក្តីសម្រេចលើសំណើសុំការព្យួរដីកាកោះ កថាខណ្ឌ ១៤។

[71] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន កថាខណ្ឌ ១០។

[72] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ តា អាន កថាខណ្ឌ ១១។

31. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ស្របជាមួយសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា ក្របខណ្ឌច្បាប់បច្ចុប្បន្នមានប្រព័ន្ធត្រួតពិនិត្យគ្រប់គ្រាន់ ដើម្បីធានាថា សកម្មភាពជាឯកតោភាគីត្រូវបានធ្វើឡើងអនុលោមទៅតាមច្បាប់[73]។ ការអនុញ្ញាតជាទូទៅឱ្យភាគីចូលពិនិត្យមើលការខ្វែងយោបល់គ្នាបន្ទាប់ពីមានការចោទប្រកាន់ថា ពួកគេចង់ពិនិត្យទៅលើសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតតែម្នាក់ក្នុងការបំពេញកិច្ចតែម្នាក់ឯង នឹងធ្វើឱ្យប៉ះពាល់ដល់គោលការណ៍សម្ងាត់នៃនីតិវិធីនៃការខ្វែងយោបល់គ្នា ហើយចុងក្រោយ នឹងធ្វើឱ្យមានការប្រែប្រួលទៅលើគោលការណ៍នេះ។ ការធានាដែលមានស្រាប់មានភាពគ្រប់គ្រាន់ដើម្បីធានាឱ្យមានការគោរពសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយសាលាក្តីដែលមានសមត្ថកិច្ច។

32. នៅក្នុងរឿងក្តីនេះ ដីកាកោះបានយោងយ៉ាងជាក់លាក់ដល់ការខ្វែងយោបល់គ្នា[74] ហើយមានការបញ្ជាក់ថា ការខ្វែងយោបល់គ្នាដែលបានលើកឡើងមិនត្រូវបានដាក់ជូនទៅអង្គបុរេជំនុំជម្រះទេ[75]។ ដីកាកោះត្រូវបានចេញនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ រយៈពេលជាង ៣០ ថ្ងៃក្រោយពេលចុះកំណត់ហេតុនៃការខ្វែងយោបល់គ្នា។ ហេតុនេះ អនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតអន្តរជាតិអាចចេញដីកាកោះបាន។ ក្នុងករណីនេះ គួរកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតទាំងពីរក៏បានយល់ស្របគ្នាចំពោះការបកស្រាយវិធាន ៧២ នៃវិធានផ្ទៃក្នុងនេះតាមរយៈសេចក្តីបំភ្លឺរួមមួយ[76] និងបានប្រមើលមើលជាមុនអំពីការវិវត្តន៍នៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះ។ កថាខណ្ឌចុងក្រោយនៃសេចក្តីបំភ្លឺរួមបានលើកឡើងថា "[សហចៅក្រមស៊ើបអង្កេត] អន្តរជាតិ នឹងបញ្ជាក់អំពីកាលបរិច្ឆេទនៃការបំពេញកិច្ចរបស់ខ្លួនខាងលើ និងនីតិវិធីនៃការជូនដំណឹង និងការប្រគល់ដីកាផ្សេងៗ ទាក់ទងទៅនឹងជនសង្ស័យ អ៊ឹម ចែម នៅក្នុងលិខិតដោយឡែករបស់ខ្លួន"[77]។ ហេតុនេះ ការចូលពិនិត្យមើលការខ្វែងយោបល់គ្នាមិនមែនជាការចាំបាច់ ដើម្បីសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានសមត្ថកិច្ចក្នុងការចេញដីកាកោះទេ។

---

[73] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ២០ ដល់ ២១។

[74] ដីកាកោះ។ *សូមមើលផងដែរ* កំណត់ហេតុនៃការប្រគល់ដីកាកោះ។

[75] ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៩។ *សូមមើលផងដែរ* សេចក្តីបំភ្លឺរួម។

[76] សេចក្តីបំភ្លឺរួម។

[77] *ដូចយោងខាងលើ*។

33. ផ្អែកទៅលើសំអាងហេតុនានាដែលបានលើកឡើងខាងលើ អង្គបុរេជំនុំជម្រះយល់ឃើញថា ពុំមានកាលៈទេសៈពិសេសនៅក្នុងរឿងក្តីនេះដែលផ្តល់យុត្តិកម្មដល់ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងទេ។ ហេតុនេះ ទាក់ទិននឹងវិធាន ២១ នៃវិធានផ្ទៃក្នុង បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

34. ហេតុនេះ បណ្តឹងឧទ្ធរណ៍នេះត្រូវតែត្រូវបដិសេធដោយសន្និដ្ឋានថាមិនអាចទទួលយកបាន។

**ហេតុនេះ អង្គបុរេជំនុំជម្រះ៖**

**សម្រេចជាឯកច្ឆន្ទ បដិសេធ**បណ្តឹងឧទ្ធរណ៍ដោយសន្និដ្ឋានថាមិនអាចទទួលយកបានទេ។

**រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គិមសាន** BEAUVALLET Olivier **ន័យ ថុល** BWANA Steven James **ហ៊ួត វុទ្ធី**